ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៤៧...សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតម្លៃលើ ផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រនៅតាមដង ផ្លូវជាតិលេខ ៥, ៦, ៥៦ និង ៦៨ ក្នុងគំរោងការកែលំអប្រព័ន្ធ ផ្លូវមហាអនុតំបន់ទន្លេមេគង្គនៅក្នុងប្រទេសកម្ពុជា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លីប្រជារាស្ត្រក្នុងគំរោងការកែលំអប្រព័ន្ធផ្លូវមហាអនុតំបន់ទន្លេមេគង្គ តាមដងផ្លូវជាតិលេខ ៥, ៦, ៥៦ និង ៦៨ ដែលមានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| ១_តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣_តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ៤_តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |

**ប្រការ ២** : គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ច :

- ចុះទៅពិនិត្យដល់ទីកន្លែងនិងធ្វើស្ថិតិលើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លីប្រជារាស្ត្រ ដែលស្ថិតនៅតាមដងផ្លូវជាតិលេខ ៥ , ៦ , ៥៦ និង ៦៨ ក្នុងគំរោងកែលំអប្រព័ន្ធផ្លូវមហាអនុតំបន់ទន្លេមេគង្គ ។
- ធ្វើការវាយតម្លៃអោយបានសមស្រប ដើម្បីមានមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចនូវថវិកាសំរាប់ដោះស្រាយជាគោលនយោបាយជូនដល់ប្រជាពលរដ្ឋ ។

**ប្រការ ៣** : គណៈកម្មការអន្តរក្រសួងនេះ អាចបង្កើតអនុគណៈកម្មការនៅតាមបណ្តាខេត្តដែលពាក់ព័ន្ធជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៤** : សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន អភិបាលខេត្តដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ_កាលប្បវត្តិ*